ឆ្នាំទី ៤ លេខ ៣៧ ថ្ងៃ ទី ០៨ ខែ តុលា ឆ្នាំ ២០០៤ រាជកិច្ច ទំព័រ ២៣០០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

លេខ :......២៣១.......បទ.ប្រក.

## ប្រកាស

## ស្តីពីការ បង្កើតក្រុមការងាររៀបចំសហគ្រាស សាធារណៈលើវិស័យទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ .
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រម លេខ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦ ២០ចុះថ្ងៃទី ២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ .
- បានឃើញអនុក្រឹត្យលេខ ២០ /អនក្រ/បក ចុះថ្ងៃទី ៣០ខែមេសាឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួង និង រដ្ឋលេខាធិការដ្ឋាន .
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ .
- បានឃើញអនុក្រឹត្យលេខ៨៦អនក្រ/បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ .
- បានឃើញអនុក្រឹត្យលេខ ០៥អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជា អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតក្រុមការងារមួយ ដើម្បីជំរុញការរៀបចំសហគ្រាសសាធារណៈ លើវិស័យទូរគមនាគមន៍ ដែលមាន សមាសភាពដូចខាងក្រោម :

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ទូរស័ព្ទ: (៨៥៥) ២៣-៧២៥៩១០/៤២៦៥១០
ទូរសារ: (៨៥៥) ២៣-៤២៦៩៩២/៤២៦០១១

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **សាវ៉ាត់** | **ខាន់** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **នួច** | **ហេង** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣-លោក | **ញាណ** | **ស្រស់** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៤- លោក | **កែវ** | **ចំរើន** | អគ្គនាយករងរដ្ឋបាល | សមាជិក |
| ៥-លោក | **គង់** | **សេង** | ទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី | សមាជិក |
| ៦-លោក | **ស៊ុប** | **សុខខួន** | ប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ | សមាជិក |
| ៧-លោក | **ឡៅ** | **សារឿន** | ប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស | សមាជិក |
| ៨-លោក | **លី** | **ណារិទ្ធិ** | អនុប្រធាននាយកដ្ឋាន ទូរគមនាគមន៍អន្តរជាតិ | សមាជិក |
| ៩-លោក | **អ៊ុច** | **មុន្នី** | អនុប្រធាននាយកដ្ឋាន ទូរគមនាគមន៍ក្នុងប្រទេស | សមាជិក |
| ១០-លោក | **គិត** | **ស្រ៊ាង** | អនុប្រធានការិយាល័យ និតិក្រម នៃនាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ | សមាជិក |

**ប្រការ២** : ក្រុមការងារនេះ មានភារកិច្ចសិក្សាស្រាវជ្រាវ រាល់បណ្តាឯកសារដែលពាក់ពន្ធ័ និងរៀបចំទំរង់បែបបទ ដើម្បីជំរុញការបង្កើតសហគ្រាសសាធារណៈលើវិស័យទូរគមនាគមន៍ដោយទំនាក់ទំនងជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៣** : ក្រុមការងារនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ ឯកឧត្តមប្រធាន។ ក្រោយពីចប់ភារកិច្ច ត្រូវ រាយការណ៍អំពីលទ្ធផលការងារជូន **ឯកឧត្តមរដ្ឋមន្ត្រី** ដើម្បីពិនិត្យ និង សុំយោបល់សំរេច ។

**ប្រការ៤** : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល-អគ្គនាយកដ្ឋានប.ទ គ្រប់នាយកដ្ឋានពាក់ព័ន្ធនិងសាមុីខ្លួនត្រូវទទួលភារកិច្ច អនុវត្តន៍ តាមខ្លឹមសារនៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ.ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤

**រដ្ឋមន្ត្រី**

**សូ ខុន**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

  ដើម្បីជូនជ្រាប "
- ដូចប្រការ៥ " ដើម្បីអនុវត្តន៍ "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ